# ច្បាប់
# ស្តីពីបាតុកម្ម

**មាត្រា ១.-**

ការប្រជុំជាពួក ជាកង និង ការប្រមូលផ្តុំគ្នាធ្វើបាតុកម្មអាចប្រព្រឹត្តទៅបាន ។ ប៉ុន្តែការប្រជុំជាពួក ជាកងនៅទីន្លែងសាធារណៈ ឬនៅលើផ្លូវសាធារណៈ ឬការប្រមូលគ្នាដើរតាមផ្លូវជាបាតុកម្មដែលអាចបង្កឱ្យខូចភាពសុខសាន្ត ខូចសណ្តាប់ធ្នាប់ ឬសន្តិសុខសាធារណៈ ត្រូវហាមឃាត់ដាច់ខាត ។

**មាត្រា ២.-**

ការប្រមូលផ្តុំគ្នាដើរតាមផ្លូវសាធារណៈជាបាតុកម្មសម្តែងមតិលើបញ្ហាអ្វីមួយនឹងអាចប្រព្រឹត្តទៅបានតែក្នុងល័ក្ខខ័ណ្ឌដូចខាងក្រោម :

១-ឥតប្រើហិង្សា ឥតមានកាន់អាវុធ ឬឧបករណ៏ដែលអាចបណ្តាលឱ្យមានគ្រោះថ្នាក់ ។

២-ឥតបង្កឱ្យខូចភាពសុខសាន្ត សណ្តាប់ធ្នាប់ ឬសន្តិសុខសាធារណៈ ។

៣-ត្រូវជំរាបជាលាយលក្ខណ៏អក្សរទៅអាជ្ញាធរឃុំ សង្កាត់នីមួយៗ ដែលបាតុកម្មត្រូវឆ្លងកាត់យ៉ាងតិច ៣ ថ្ងៃមុន ដោយមានចុះនាមត្រកូល នាមខ្លួន អាស័យដ្ឋាន និងហត្ថលេខានៃអ្នករៀបចំបាតុកម្ម ៣ នាក់ ព្រមទាំងបញ្ជាក់គោលបំណងនៃបាតុកម្ម ទីកន្លែង ថ្ងៃ ខែ ឆ្នាំ ម៉ោង នៃការប្រជុំ ផ្លូវ និងមនុស្សដែលត្រូវដង្ហែរក្បួនបាតុកម្ម ។

បើបាតុកម្ម ធ្វើនៅទីរួមខេត្ត ឬនៅរដ្ឋធានី ត្រូវជំរាបជាលាយលក្ខណ៏អក្សរទៅអាជ្ញាធរទីរួមខេត្ត ឬទៅអាជ្ញាធររដ្ឋធានី ។

**មាត្រា ៣.-**

អាជ្ញាធរដែលបានទទួលលិខិតជូនដំណឹង ត្រូវចេញបង្កាន់ដៃមួយអោយ ។

បើអាជ្ញាធរសាមីយល់ឃើញថា បាតុកម្មមានលក្ខណៈដែលអាចនាំឱ្យកើតមានចលាចល នោះអាជ្ញាធរសាមីអាចហាមឃាត់បាតុកម្មដោយចេញសេចក្តីសំរេចមួយក្នុងរយៈពេល ៤៨ ម៉ោង ហើយឱ្យដំណឹងអំពីសេចក្តីសំរេចនោះដល់អ្នករៀបចំបាតុកម្មវិញភ្លាម ។

សេចក្តីចម្លងមួយច្បាប់នៃសេចក្តីសំរេចនោះ ត្រូវផ្ញើជូនថ្នាក់លើជ្រាបក្នុងរយៈពេល ២៤ម៉ោង ។

ក្នុងករណីមិនសុខចិត្ត អ្នករៀបចំបាតុកម្មអាចធ្វើបណ្តឹងតវ៉ាទៅអាជ្ញាធរថ្នាក់លើ ។

អាជ្ញាធរថ្នាក់លើត្រូវសំរេចលើពាក្យតវ៉ានេះថា ឱ្យ ឬមិនឱ្យ ហើយឱ្យដំណឹងអំពីសេចក្តីសំរេចរបស់ខ្លួននេះដល់ម្ចាស់បណ្តឹងភ្លាម ក្នុងរយៈពេល ២៤ ម៉ោង ។

**មាត្រា ៤.-**

កាលបើមានបាតុកម្មកើតឡើងដោយមិនបានជំរាបអាជ្ញាធរមូលដ្ឋានជាមុន ឬដោយអាជ្ញាធរមូលដ្ឋានមិនបានអនុញ្ញាត អាជ្ញាធរមូលដ្ឋានអាចចាត់វិធានការណ៏ឃាត់បាតុករដល់ទីកន្លែង ។



Downloaded from http://www.khmerlaws.com

បើក្រោយពីបានដាក់កំហិតឱ្យឈប់ពីរដងហើយ បាតុករនៅតែរឹងរូស មិនព្រមបញ្ឈប់សកម្មភាពរបស់ខ្លួន អាជ្ញាធរមូលដ្ឋានត្រូវចាត់វិធានការណ៍បំបែកជួរបាតុករ ដោយប្រើឧបករណ៍គ្មានគ្រោះថ្នាក់ដល់អាយុជីវិត ។

**មាត្រា ៥.-**

ក្នុងករណីបាតុករមានកាន់អាវុធ ឬឧបករណ៍ដែលអាចបណ្តាលអោយមានគ្រោះថ្នាក់ នោះកងកម្លាំងរក្សាសន្តិសុខមានសិទ្ធិដកហូតអាវុធ និងឧបករណ៍ទាំងនោះ ។ បើបាតុកររឹងរូសមិនព្រមប្រគល់អាវុធ និងឧបករណ៍ទាំងនោះទេ កងកម្លាំងរក្សាសន្តិសុខមានសិទ្ធិឃាត់ខ្លួនបាតុករ និងដកហូតអាវុធ និងឧបករណ៍ជាបណ្តោះអាសន្ន ។

លុះដល់បាតុកម្មបាន ស្ងប់ស្ងាត់វិញហើយ ត្រូវដោះលែងជនឃាត់ខ្លួន ព្រមទាំងប្រគល់អាវុធ ឬឧបករណ៍ឱ្យសាមីខ្លួនវិញលើកលែងតែមានបទល្មើសអ្វីផ្សេងទៀត ។

**មាត្រា ៦.-**

ក្នុងករណីបាតុកម្មដោយសន្តិវិធី ក្លាយទៅជាបាតុកម្មហិង្សា ឬកុប្បកម្ម អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់វិធានការយ៉ាងសមស្របបំផុត ដើម្បីបញ្ឈប់បាតុកម្ម ឬកុប្បកម្មនោះ ។

វិធានការដែលមានចែងក្នុងមាត្រា ៤ ត្រូវយកមកអនុវត្ត ជាបឋម ។

**មាត្រា ៧.-**

បាតុករណាដែលប្រើហិង្សាបណ្តាលអោយអន្តរាយដល់ទ្រព្យសម្បត្តិរបស់អ្នកដទៃ ឬទ្រព្យសម្បត្តិសាធារណៈ ឬបណ្តាលឱ្យមានរបួសស្នាម ឬបាត់បង់អាយុជីវិតអ្នកដទៃ ឬភ្នាក់ងាររដ្ឋការកំពុងបំពេញបេសកម្មត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ដោយយោលទៅតាមកំរិតធ្ងន់ ឬស្រាលនៃបទល្មើសដែលបានប្រព្រឹត្ត ។

អ្នកក្លែងបន្លំ អុចអាល ញុះញង់ឱ្យប្រើហិង្សា ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមានដូចខាងលើនេះដែរ ។

**មាត្រា ៨.-**

ភ្នាក់ងាររដ្ឋការដែលកំពុងបំពេញភារកិច្ចនៅពេលបាតុកម្ម ហើយបានប្រព្រឹត្តអំពើខុសច្បាប់ បណ្តាលអោយអន្តរាយដល់ទ្រព្យសម្បត្តិរបស់ប្រជាជន ឬទ្រព្យសម្បត្តិសាធារណៈ ឬបណ្តាលឱ្យមានរបួសស្នាម ឬបាត់បង់អាយុជីវិតអ្នកដទៃត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ដោយយោលទៅតាមកំរិតធ្ងន់ ឬស្រាលនៃបទល្មើសដែលបានប្រព្រឹត្ត ។

**មាត្រា ៩.-**

ជនណាដែលឆ្លៀតយកឱកាសបាតុកម្ម ដើម្បីប្រព្រឹត្តអំពើលួច ឆក់ ប្លន់ ឬអំពើល្មើសផ្សេងទៀត ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ដោយយកអតិបរមានៃទោសមកអនុវត្ត ។

**មាត្រា ១០.-**

ការជួសជុលការខូចខាតទាំងឡាយដែលបណ្តាលមកពីបាតុកម្ម ត្រូវជាបន្ទុករបស់ថវិកាខេត្ត ឬថវិកាក្រុងសាមី ។ បើការខូចខាតនេះបណ្តាលមកពីកំហុស ឬការធ្វេសប្រហែសរបស់ជនរងគ្រោះនោះ ការជួសជុលនៃការខូចខាតត្រូវបន្ថយ ឬបាត់ទាំងស្រុង ។



Downloaded from http://www.khmerlaws.com

ក្នុងករណីដែលអាជ្ញាធរមានសមត្ថកិច្ចរកឃើញជនល្មើស អាជ្ញាធរខេត្ត ក្រុង អាចប្តឹងបកអោយជនល្មើសនោះសង ថ្លៃជួសជុលការខូចខាតខាងលើនេះមកថវិកាខេត្ត ក្រុងវិញ ។

**មាត្រា ១១.-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ច្បាប់នេះ ត្រូវបានរដ្ឋសភានៃរដ្ឋកម្ពុជាអនុម័តនៅថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៩១ នាសម័យប្រជុំវិសាមញ្ញ នៃនីតិកាល ទី ១ ។

ភ្នំពេញ ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៩១

ជ.រដ្ឋសភា

ប្រធាន

ហត្ថលេខា និងត្រា

ជា ស៊ីម

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

អគ្គលេខាធិការ ក្រុមប្រឹក្សារដ្ឋ

ហត្ថលេខា និងត្រា : ចាន់ វ៉ែន



Downloaded from http://www.khmerlaws.com